២០១៩

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ២៧០៩ MIH / ២០១៩

ថ្ងៃ សុក្រ ៤រោច ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១៩

## សេចក្ដីជូនដំណឹង

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក លោកស្រី ជាម្ចាស់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ឱ្យបានជ្រាបថា៖ ដើម្បីពង្រឹង និងសម្រួលលើការស្នើសុំលិខិតបញ្ជាក់មុខសញ្ញា និងស្តង់ដារប្រើប្រាស់សារជាតុគីមី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានចាប់ផ្តើមអនុវត្តនូវការស្នើសុំលិខិតបញ្ជាក់មុខសញ្ញា និងស្តង់ដារប្រើប្រាស់សារជាតុគីមីសម្រាប់បម្រើឱ្យវិស័យឧស្សាហកម្ម និងសិប្បកម្មនេះ តាមប្រព័ន្ធបញ្ជរតែមួយជាតិ (Online) តាមរយៈគេហទំព័រ https://live.nsw.gov.kh ។

ការស្នើសុំលិខិតបញ្ជាក់មុខសញ្ញា និងស្តង់ដារប្រើប្រាស់សារជាតុគីមីតាមប្រព័ន្ធបញ្ជរតែមួយជាតិ (Online) នេះ ក្នុងគោលបំណង ដើម្បីជួយសម្រួលដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្ម ឱ្យទទួលបាននូវភាពងាយស្រួល កាត់បន្ថយពេលវេលា ធ្វើឱ្យមានតម្លាភាព និងប្រសិទ្ធភាព ក្នុងការផ្តល់សេវាកម្មសម្រាប់ការស្នើសុំលិខិតបញ្ជាក់ខាងលើ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីជាម្ចាស់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្មទាំងអស់ មេត្តាជ្រាប និងចូលរួមសហការអនុវត្តតាមការជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**
- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- រដ្ឋបាលរាជធានី-ខេត្ត
- គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ